អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ...០៤៥............អ.ស.ហ.ប្រក.

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់វិស័យឯកជន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមតម្រូវការចាំបាច់របស់និយ័តករគណនេយ្យនិងសវនកម្ម

## **សម្រេច**

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់វិស័យឯកជន ដែលសរសេរអក្សរកាត់ថា "**គ.ប.អ.ស.**" ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | ប្រធាន |
| - អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម ចំនួន២រូប | អនុប្រធាន |
| - តំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ចំនួន៣រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម ចំនួន១រូប | សមាជិក |
| - តំណាងធនាគារជាតិនៃកម្ពុជា ចំនួន១រូប | សមាជិក |
| - តំណាងនិយ័តករនិងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ចំនួន៦រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានពន្ធដារ ចំនួន១រូប | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា ចំនួន៣រូប | សមាជិក |
| - តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ចំនួន១រូប | សមាជិក |
| - ទីប្រឹក្សាបច្ចេកទេស របស់ ន.គ.ស. | សមាជិក |
| - តំណាង ន.គ.ស. ចំនួន៣រូប | សមាជិក |
| - តំណាងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្ម ជាសមាជិកសកម្មរបស់ វ.គ.ស.ក. ចំនួន៤រូប | សមាជិក។ |

តំណាងក្រសួង ស្ថាប័ន និងវិស័យឯកជន ដែលត្រូវបានចាត់ឱ្យចូលរួមជាសមាសភាពនៃ **គ.ប.អ.ស.** ត្រូវតែជាមន្ត្រីបច្ចេកទេសជំនាញគណនេយ្យនិង/ឬសវនកម្ម និងត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់អគ្គនាយកនៃ **ន.គ.ស.**។

ប្រធាន **គ.ប.អ.ស.** អាចស្នើសុំបន្ថែម ឬ បន្ថយសមាសភាពសមាជិក តាមការចាំបាច់។

ប្រធាន អនុប្រធាន និងសមាជិក នៃ **គ.ប.អ.ស.** មានអាណត្តិរយៈពេល ៣ (បី) ឆ្នាំ។

**គ.ប.អ.ស.** អាចអញ្ជើញអ្នកជំនាញ និងតំណាងភាគីពាក់ព័ន្ធ ដើម្បីចូលរួមផ្តល់យោបល់លើប្រធានបទនានាពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ២.**_

**គ.ប.អ.ស.** មានមុខងារនិងភារកិច្ច ដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់លើបច្ចេកទេសស្តង់ដាពាក់ព័ន្ធ និងបញ្ហាប្រឈមនៃការអនុវត្តស្តង់ដាជាធរមាន
- ស្នើវិធានការអនុវត្តស្តង់ដាជូន **ន.គ.ស.** ក្នុងបរិការណ៍សេដ្ឋកិច្ច វិនិយោគ ធុរកិច្ច និងសង្គមនៅកម្ពុជា

- សិក្សា និងស្រាវជ្រាវអំពីបញ្ហាប្រឈម និងស្នើដំណោះស្រាយលើបញ្ហាប្រឈមនិងគោលការណ៍ណែនាំអនុវត្តស្តង់ដាពាក់ព័ន្ធ និងលើកសំណើជូន **ន.គ.ស**.
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តង់ដាដែលលើកឡើងដោយវិស័យឯកជន
- ពិនិត្យ និងផ្តល់យោបល់លើអត្ថបទបកប្រែជាភាសាខ្មែរ សម្រាប់ស្តង់ដាពាក់ព័ន្ធនានា ជាធរមាន
- អនុវត្តមុខងារភារកិច្ចមួយចំនួនទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ**.។

**ប្រការ៣._**

នាយកដ្ឋានបច្ចេកទេសនៃ **ន.គ.ស**. ជាលេខាធិការដ្ឋានរបស់ **គ.ប.អ.ស**. និងដើរតួនាទីជាសេនាធិការរដ្ឋបាល និងបច្ចេកទេស។ ប្រធាន ឬ អនុប្រធាននាយកដ្ឋានបច្ចេកទេស ជាប្រធានលេខាធិការដ្ឋាន និងមានអនុ-ប្រធាននិងសមាជិកមួយចំនួន។ ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយសេចក្តីសម្រេចរបស់អគ្គនាយកនៃ **ន.គ.ស**.។

**ប្រការ៤._**

អនុប្រធាន និងសមាជិក នៃ **គ.ប.អ.ស**. ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ លិខិតអញ្ជើញរបៀបវារៈ និងឯកសារពាក់ព័ន្ធ ត្រូវផ្ញើជូនប្រធាន អនុប្រធាន និងសមាជិក យ៉ាងហោចណាស់ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកិច្ចប្រជុំ វៀរលែងតែកិច្ចការបន្ទាន់។ ក្នុងករណីអវត្តមានប្រធាន **គ.ប.អ.ស**. ត្រូវផ្ទេរសិទ្ធិជូន អនុប្រធានដើម្បីដឹកនាំប្រជុំជំនួស ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពនៃការអនុវត្តមុខងារភារកិច្ចរបស់ **គ.ប.អ.ស**.។

កិច្ចប្រជុំរបស់ **គ.ប.អ.ស**. អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់។ ក្នុងករណីដែលកិច្ចប្រជុំលើកទីមួយមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុខ្វះកូរ៉ុម ប្រធានអាចកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរបាន ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំលើកទីមួយ។ ការប្រជុំលើកទីពីរនេះ មិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានមិនបានប្រជុំតាមការអញ្ជើញលើកទីមួយប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់ **គ.ប.អ.ស**. អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព។

**ប្រការ៥._**

រាល់កិច្ចប្រជុំរបស់ **គ.ប.អ.ស**. ត្រូវមានកំណត់ហេតុ។

សេចក្តីសម្រេចរបស់ **គ.ប.អ.ស**. ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំ និងលេខាកត់ត្រា។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃ **គ.ប.អ.ស**. ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។

**គ.ប.អ.ស.** ត្រូវធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពការងារជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ៦._**

លាភការរបស់ប្រធាន អនុប្រធាន និងសមាជិក នៃ **គ.ប.អ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់ប្រធាន **គ.ប.អ.ស.**។

**ប្រការ៧._**

**គ.ប.អ.ស.** ប្រើប្រាស់ថវិការបស់ **ន.គ.ស.** ដើម្បីបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ស្របតាមប្រកាសនេះ។

**គ.ប.អ.ស.** អាចប្រើប្រាស់ត្រារបស់ **ន.គ.ស.** ដើម្បីដំណើរការការងាររបស់ខ្លួនបាន។

**ប្រការ៨._**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ក្រុមហ៊ុនគណនេយ្យ និង/ឬសវនកម្ម និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា គ.ស.២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាននៃ អ.ស.ហ.
- និយ័តករគណនេយ្យនិងសវនកម្ម
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ